ពលរដ្ឋខ្លាំង ជាតិខ្លាំង
STRONG PEOPLE STRONG NATION

# វេទិកាពលរដ្ឋ
# FORUM FOR THE PEOPLE

សហរដ្ឋអាមេរិក ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២

## សេចក្តីថ្លែងការណ៍
## ការចាប់ខ្លួនលោក ផែល ធីលែន
## ជាការលើកតម្កើងមហិច្ចតាឈ្លានពានរបស់វៀតណាម

**វេទិកាពលរដ្ឋ** ថ្កោលទោសអាជ្ញាធរនៃលោក **ហ៊ុន សែន** ដែលបានចាប់ខ្លួនសកម្មជនសង្គម លោក **ផែល ធីលែន** យ៉ាងតក់ក្រហល់ ខណៈពេលយុវជនរូបនេះ ធ្វើយុទ្ធនាការបាតុកម្មអហិង្សា ទាមទារឲ្យរដ្ឋាភិបាល ទម្លាក់ចោលគម្រោងផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនអន្តោប្រវេសន្តនៅកម្ពុជា ដែលស្ទើរតែទាំងអស់ ជាជនអន្តោប្រវេសន្តវៀតណាមខុសច្បាប់ និង ស្នើរំសាយផែនការបង្កើតដេប៉ាតឺម៉ង់(Département)ភាសាវៀតណាម នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ការលេចចេញភ្លាមៗនូវដីកាបង្គាប់ឲ្យឃុំខ្លួន លោក **ផែល ធីលែន** ភ្ជាប់សាច់រឿង«លួចលក់អចលនវត្ថុរបស់អ្នកដទៃ» តាំងពីអំឡុងឆ្នាំ២០១៦ នៅចំពេលយុវជន **ផែល ធីលែន** ធ្វើសកម្មភាពតស៊ូមតិការពារពូជសាសន៍ខ្មែរនៅពេលនេះ នោះបង្ហាញពីចំណាត់ការដែលមានចរិតអាជ្ញាទំនើងចិត្ត បំបាក់ស្មារតីកូនខ្មែរ ដែលមានឆន្ទៈគិតគូរអាយុជីវិតជាតិខ្មែរ។ វាពិតជារឿងអកុសលខ្លាំងណាស់ សម្រាប់ពូជសាសន៍ខ្មែរយើង ដែលបច្ចុប្បន្នមានរដ្ឋាភិបាលលោក **ហ៊ុន សែន** ហ៊ានប្រើគ្រប់ឧបាយកល ក្នុងការបំផ្លាញទឹកចិត្តតស៊ូដើម្បីជាតិខ្មែររបស់កូនខ្មែរ ក្នុងគោលដៅជ្រោមជ្រែងយុទ្ធសាស្ត្រឈ្លានពានរបស់វៀតណាម។

**វេទិកាពលរដ្ឋ** ពិតជាសោកស្តាយពន់ពេក ដែលរដ្ឋាភិបាលលោក **ហ៊ុន សែន** ជាមិត្តដ៏ស៊ីជម្រៅរបស់វៀតណាម មិនរៀនមេរៀនលើកទឹកចិត្តប្រជាពលរដ្ឋខ្មែរ ឲ្យការពារអធិបតេយ្យជាតិខ្មែរ ដូចគំរូរបស់មេដឹកនាំវៀតណាម ដែលបំពាក់ស្មារតីជាតិដល់ពលរដ្ឋរបស់គេ។ មេរៀនគំរូ ដែលមេដឹកនាំវៀតណាមអនុវត្តសម្រាប់ពង្រឹងស្មារតីការពារជាតិខ្លួន គឺក្នុងខែមិថុនា ឆ្នាំ២០១៨ រដ្ឋាភិបាលវៀតណាម មិនត្រឹមតែមិនធ្វើទុក្ខបុកម្នេញបាតុករវៀតណាមនោះទេ ថែមទាំងបានលើកសរសើរនូវពាក្យ «ជាអ្នកការពារទឹកដីវៀតណាមដ៏អង់អាចក្លាហាន» ទោះបីជាបាតុករទាំងនោះ បានធ្វើបាតុកម្មប្រឆាំងនឹងការវិនិយោគដីសម្បទានរបស់ក្រុមហ៊ុនចិន រហូតដល់ក្លាយជាកុប្បកម្ម ដុតបំផ្លាញទ្រព្យសម្បត្តិសាធារណៈអស់ជាច្រើនក៏ដោយ។

យើងខ្ញុំមើលឃើញថា បើដ្ឋាភិបាលលោក **ហ៊ុន សែន** មិនធ្វើជាឧបករណ៍ឈ្លានពានរបស់វៀតណាមទេ គួរណាស់ រៀនមេរៀនលើកទឹកចិត្តពលរដ្ឋខ្មែរ ឲ្យការពារជាតិខ្មែរ ដូចមេដឹកនាំវៀតណាម ដែលលើកតម្កើងប្រជាជនរបស់គេដែរ។ តាមគំរូនេះ លោក **ផែល ធីលែន** និង **សកម្មជនសង្គមឯទៀត** ត្រូវតែទទួលបានការដោះលែងឲ្យមានសេរីភាព ពីសកម្មភាពតស៊ូមតិអហិង្សារបស់ពួកគាត់ ដើម្បីបុព្វហេតុជាតិ។ បើមិនដូច្នោះទេ លោក **ហ៊ុន សែន** គឺជាភ្នាក់ងារបន្តសម្រួលការឈ្លានពានរបស់វៀតណាម មិនអាចប្រកែកបាន។ ឈ

**អគ្គលេខាធិការ**

**អ៊ាប គីមសេង**

Address: 58 Poplar Street, Plains PA 18 705, USA